សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក /អជសជ

# អនុស្សរណៈអន្តរការិយាល័យ

**ផ្ញើជូន**: លោកស្រី Susan Lamb, មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់, អង្គជំនុំជម្រះសាលាដំបូង នៃ អវតក

កាលបរិច្ឆេទ: ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២

**អ្នកផ្ញើ**: លោកស្រី ជា លាង និង លោក William Smith, សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង

**ចម្លងជូន**:
- អង្គជំនុំជម្រះសាលាដំបូង
- គ្រប់ភាគីទាំងអស់ នៃសំណុំរឿង០០២។

**កម្មវត្ថុ**: ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី ពាក់ព័ន្ធនឹងឯកសារនានាដែលអ្នកជំនាញប្រើប្រាស់សម្រាប់ការផ្តល់សក្ខីកម្មរបស់ខ្លួន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២។

លោកស្រី Lamb ជាទីគោរពរាប់អាន,

ជាគោលការណ៍ សហព្រះរាជអាជ្ញាមិនមានការជំទាស់ទៅនឹងសំណើដែលសហមេធាវីការពារក្តី អៀង សារី បានលើកទាក់ទងនឹងការត្រៀមរៀបចំរបស់អ្នកជំនាញនោះទេ។ យើងយល់ស្របថា សំណើនេះនឹងជួយដល់គ្រប់ភាគីទាំងអស់ ដើម្បីទទួលបាននូវការជូនដំណឹងជាមុន អំពីប្រភពនៃឯកសារនានាដែលអ្នកជំនាញអាចនឹងត្រូវលើកយកមកពិនិត្យនៅក្នុងពេលត្រៀមរៀបចំរបស់ខ្លួន នៅមុនពេលត្រូវផ្តល់សក្ខីកម្ម។ យើងក៏សូមធ្វើការកត់សម្គាល់ជូនផងដែរថា ដោយសារសាក្សីទាំងនេះគឺជាអ្នកជំនាញ ការធ្វើសក្ខីកម្មរបស់គាត់ជៀសមិនផុតពីការដកស្រង់យកមកពីក្នុងប្រភពឯកសារនានា និងពីការយល់ដឹងដែលឯកសារទាំងអស់នេះមិនអាចធ្វើទៅជាបញ្ជីបានឡើយ។

យើងបានផ្តល់ជូននូវបញ្ជីរាយឈ្មោះប្រធានបទនានាសម្រាប់ឱ្យអ្នកជំនាញ និងបានលើកយោងទៅលើសៀវភៅជាក់លាក់មួយចំនួន ព្រមទាំងទៅលើជំពូកផ្សេងៗនៅក្នុងសៀវភៅទាំងនោះ ដែលនៅក្នុងករណីខ្លះ

គឺអ្នកជំនាញទាំងនោះជាអ្នកសរសេរ។ ហេតុដូចនេះ ភាគីទាំងឡាយត្រូវបានជូនដំណឹងឲ្យបានជ្រាបរួច ហើយអំពីប្រធានបទដែលនឹងត្រូវលើកយកមកពិភាក្សា។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំរំពឹងទុកជាមុនថា អ្នកជំនាញទាំងឡាយអាចពិនិត្យមើលឡើងវិញនូវប្រភពឯកសារពីក្នុងសៀវភៅរបស់ខ្លួន និងឯកសារចេញពីក្នុងសំណុំរឿងលេខ០០២ គឺវាអាស្រ័យទៅលើការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ក៏ប៉ុន្តែការណ៍នេះជៀសមិនផុតមិនបានឡើយ។

អាស្រ័យហេតុនេះ យើងស្នើថា គួរតែបញ្ជាក់ឲ្យច្បាស់ដល់អ្នកជំនាញថា ដើម្បីនឹងផ្តល់សក្ខីកម្ម គឺមិនមានតម្រូវឲ្យអ្នកជំនាញ៖

(១) ត្រូវតែពិនិត្យមើលគ្រប់ប្រភពនៃឯកសារទាំងអស់ដែលមាននៅក្នុងសៀវភៅ ឬនៅក្នុងអត្ថបទរបស់ខ្លួននោះឡើយ និង

(២) ត្រូវតែផ្តល់បញ្ជី ឬឯកសារដែលខ្លួនមានបំណងលើកឡើងយោង ដោយប្រយោលនៅក្នុងសក្ខីកម្មរបស់ខ្លួននោះឡើយ។

អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានធ្វើការពិនិត្យឡើងវិញដោយសើរៗទៅលើលិខិតដែលបានព្រាងឡើងដោយមេធាវីការពារក្តី អៀង សារី ដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូង (**ឧបសម្ព័ន្ធ** ក) និងស្នើឲ្យបញ្ជូនលិខិតដែលបានពិនិត្យឡើងវិញនោះ ជូនទៅអ្នកជំនាញខាងលើ៕

ដោយសេចក្តីគោរពរាប់អាន

# ឧបសម្ព័ន្ធ ក

ខែមិថុនា ឆ្នាំ២០១២

អាសយដ្ឋាន

អ្នកជំនាញជាទីរាប់អាន

ដូចដែលលោកបានជ្រាបស្រាប់ហើយថា ក្នុងពេលឆាប់ៗនេះគេនឹងកោះហៅលោកឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ យើងយល់ឃើញថា ថ្មីៗនេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ(WESU) ធ្លាប់បានផ្តល់ជូនលោកនូវបញ្ជីប្រធានបទនានាដែលភាគីមួយចំនួនអាចនឹងត្រូវតាំងសំណួរដល់រូបលោក។

យើងជូនប្រឹក្សាយោបល់ថា លោកមិនជាប់កាតព្វកិច្ចត្រូវធ្វើការពិនិត្យលើឯកសារទាំងនោះ អំពីថាតើសៀវភៅទាំងឡាយរបស់លោក ឬអត្ថបទនានាដែលលោកបានសរសេរ មានប្រភពមកពីណានោះទេ ឬផ្ទុយទៅវិញ។

ទោះជាយ៉ាងណាក៏ដោយ បើសិនលោកសម្រេចតាមការស្ម័គ្រចិត្តរបស់លោកថាត្រូវធ្វើដូច្នេះ ដើម្បីជម្រុញឲ្យមានតម្លាភាព និងដើម្បីជួយដល់ភាគីនានា នៅក្នុងការត្រៀមរៀបចំធ្វើជាសំណួរសម្រាប់សួរដល់រូបលោក សូមស្នើឲ្យលោក៖

(១) ធ្វើបញ្ជីមួយស្តីពីឯកសារនានាដែលលោកធ្លាប់បានពិនិត្យឡើងវិញរួចហើយ ក្នុងការត្រៀមរៀបចំរបស់លោក ឬស្តីពីឯកសារនានាដែលលោកមានបំណងនឹងយោងដោយផ្ទាល់ នៅក្នុងសក្ខីកម្មរបស់លោក។ (ឧទាហរណ៍ បើលោកពិនិត្យឡើងវិញឯកសារដែលបានជ្រើសរើសចេញពីកំណត់សម្គាល់ជើងទំព័រក្នុងសៀវភៅរបស់លោកនោះ វាជាការមានប្រយោជន៍ បើលោកបានបញ្ជាក់ថាតើកំណត់សម្គាល់ជើងទំព័រមួយណា ដែលលោកបានពិនិត្យ), និង

(២) ផ្តល់ជូនដល់ WESU នូវសំណៅចម្លងមួយច្បាប់ស្តីពីបញ្ជីឯកសារណាមួយ ដែលបានពិនិត្យឡើងវិញ និងសំណៅចម្លងនានាស្តីពីឯកសារទាំងនោះ បើសិនលោកអាចបើកចូលមើលឯកសារអេឡិចត្រូនិចទាំងនោះបាន នៅក្នុងរយៈពេលចំនួនមួយសប្តាហ៍មុនពេលដែលលោកបានអញ្ជើញមកដល់ អ.វ.ត.ក។

បើលោកត្រូវយោងទៅដល់ឯកសារនានាដែលមាននៅក្នុងការត្រៀមរៀបចំរបស់លោក ដែលមិនអាចមានលទ្ធភាពអានវាបានជាអេឡិចត្រូនិច ឬមិនអាចបើកចូលមើលវាបាននៅក្នុងប្រទេសកម្ពុជានោះ វាអាចជាជំនួយមួយដ៏ប្រសើរបំផុត បើលោកអាចផ្តល់ឯកសារទាំងនោះជូនដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញបាន នៅពេលដែលលោកអញ្ជើញមកដល់ ប្រយោជន៍ដើម្បីឲ្យគេបានស្កាន់ឯកសារទាំងនោះ និងបង្វិលវាជូនលោកវិញ។

សូមលោកទទួលនូវការរាប់អាន,

ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង / មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង


ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh